ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨



# មាតិកា

**ល.រ បរិយាយ** **លេខទំព័រ**


I- កិច្ចប្រជុំជំនាញបច្ចេកទេស

- សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ១-៤

II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA )

- កិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាមួយក្រុមការងារRIA នៃក្រសួងយុត្តិធម៌ ៥-៨

III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨ ៩-១១

# សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា

កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុច ថោងសេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខឃាត់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី **ការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងទេសចរណ៍។





អនុវត្តតាមមាត្រា២០ នៃច្បាប់ស្តីពីទេសចរណ៍ ដែលតម្រូវឲ្យក្រសួងទេសចរណ៍រៀបចំបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ក្នុងភាពជាដៃគូជាមួយផ្នែកឯកជន និងផ្នែកសាធារណៈ ក្រសួងទេសចរណ៍បានសម្រេចរៀបចំឡើងនូវសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ក្នុងគោលបំណងធានាបាននូវភាពស៊ីសង្វាក់គ្នា និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងភាគីរដ្ឋ និងភាគីឯកជនពាក់ព័ន្ធនៅក្នុងវិស័យទេសចរណ៍ ពិសេសធានាការទទួលបាននូវធាតុចូលសំខាន់ៗដែលចូលរួមចំណែកជំរុញការផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិឲ្យកាន់តែទូលំទូលាយ ក៏ដូចជាចូលរួមដល់ការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈលំហូរចូលនៃភ្ញៀវទេសចរណ៍អន្តរជាតិផងដែរ។

ជាការពិតណាស់ វិស័យទេសចរណ៍ ជាវិស័យដែលនាំមកនូវកំណើនការងារ នាំមកនូវការបង្កើតមុខរបរ នាំមកនូវប្រាក់ចំណូលដែលចាក់បញ្ចូលទៅក្នុងសេដ្ឋកិច្ចជាតិ ពោលវិស័យទេសចរណ៍ គឺជាការជំរុញការនាំចេញនៅនឹងកន្លែង និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជា “មាសបៃតង”។ ជាក់ស្តែងកាលពីឆ្នាំ២០១៧កន្លងទៅនេះ កំណើនភ្ញៀវអន្តរជាតិដែលមកកាន់ព្រះរាជាណាចក្រកម្ពុជា មានចំនួនប្រមាណជាង ៥ លាន ៦ សែននាក់ ហើយវិស័យទេសចរណ៍មានចំណែករហូតទៅដល់ជាង ១៣% នៃផលិតផលក្នុង

ស្រុកសរុប។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០២០ ជាឆ្នាំគោល ដើម្បីជំរុញទាក់ទាញទេសចរណ៍អន្តរជាតិឲ្យមកទស្សនាកម្ពុជាឲ្យបានប្រមាណ ៧ លាននាក់ និងធ្វើឲ្យកម្ពុជាត្រូវបានទទួលស្គាល់ថា ជាគោលដៅទេសចរណ៍លំដាប់ពិភពលោកប្រកបដោយភាពកក់ក្ដៅ "កម្ពុជាៈព្រះរាជាណាចក្រអច្ឆរិយៈផ្ដល់ភាពកក់ក្ដៅ"។ ដោយមើលឃើញពីសារៈសំខាន់នៃវិស័យទេសចរណ៍ មានទៅលើសេដ្ឋកិច្ច និងសង្គមជាតិ និងពិសេសដើម្បីសម្រេចបាននូវគោលដៅនេះ វាទាមទារចាំបាច់ឲ្យមានការយកចិត្តទុកដាក់ និងចាត់វិធានការនៅក្នុងកិច្ចខិតខំប្រឹងប្រែងបន្តការជំរុញផ្សព្វផ្សាយ និងទាក់ទាញភ្ញៀវទេសចរបរទេសមកទស្សនាកម្ពុជាជាបន្ថែមទៀត។ យ៉ាងណាមិញ យើងសង្កេតឃើញថា ការផ្សព្វផ្សាយទេសចរណ៍កម្ពុជានៅក្រៅប្រទេសនាពេលបច្ចុប្បន្ននៅមានកម្រិត ដែលពុំទាន់ឆ្លើយតបឲ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការរបស់ពិភពលោកនៅឡើយ។

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមដែលកំពុងជួបប្រទេះនៅក្នុងការផ្សព្វផ្សាយពីទេសចរណ៍កម្ពុជានៅក្រៅប្រទេសនាពេលបច្ចុប្បន្នគួរឲ្យកត់សម្គាល់ពីការផ្សព្វផ្សាយទេសចរណ៍នៅក្រៅប្រទេសនៅពុំទាន់មានការចូលរួម និងទទួលបានកិច្ចសហការគាំទ្រពីភាគីឯកជនយ៉ាងពេញលេញនៅឡើយ ដែលជាហេតុធ្វើឲ្យការផ្សព្វផ្សាយទេសចរណ៍កម្ពុជាពុំបានទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់។ ម្យ៉ាងវិញទៀត បើទោះបីជាតាមការប៉ាន់ប្រមាណបានឲ្យឃើញថា នៅកម្ពុជាមួយឆ្នាំៗការចំណាយរបស់ភាគីឯកជននៅក្នុងការផ្សព្វផ្សាយទេសចរណ៍កម្ពុជានៅបរទេស មានចំនួនប្រមាណជាងមួយលានដុល្លារអាមេរិកក្នុងមួយឆ្នាំៗក៏ដោយ ប៉ុន្តែយើងពុំអាចក្ដោបក្ដាប់បាននូវចំនួនតួលេខនៃការចូលរួម និងធនធានចំណាយពិតប្រាកដនៅក្នុងការផ្សព្វផ្សាយទេសចរណ៍នៅក្រៅប្រទេសបាននៅឡើយ។ ទន្ទឹមនឹងនេះផងដែរ ផែនការនៃការផ្សព្វផ្សាយ



និងការចូលរួមរបស់ភាគីឯកជនទាំងនោះនៅពុំទាន់មានភាពស៊ីសង្វាក់ជាមួយគ្នានៅឡើយ ដែលជាហេតុធ្វើឲ្យមានផលលំបាកនៅក្នុងការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យសកម្មភាពផ្សព្វផ្សាយទេសចរណ៍ប្រកបដោយប្រសិទ្ធភាពនៅឡើយ។

ក្នុងន័យនេះ ដើម្បីឆ្លើយតប និងដោះស្រាយនឹងបញ្ហាប្រឈមដែលកំពុងជួបប្រទេះខាងលើទាំងនោះ ក្រសួងទេសចរណ៍សម្រេចរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជានេះឡើង ដើម្បីជំរុញភាពជាដៃគូនិងការចូលរួមរវាងភាគីរដ្ឋ និងភាគីឯកជននៅក្នុងការផ្សព្វផ្សាយទេសចរណ៍កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិនៅលើពិភពលោក ព្រមជាមួយនឹងការធានាបាននូវការជំរុញអភិវឌ្ឍន៍ភាពឆ្នៃប្រឌិតបង្កើតថ្មី ការរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេលវែង នៅក្នុងការផ្សព្វផ្សាយ និងទាក់ទាញភ្ញៀវទេសចរអន្តរជាតិ និងកិច្ចសហការនៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ដើម្បីឲ្យវិស័យមួយនេះ នឹងបន្តនៅជាសសរគ្រឹះសេដ្ឋកិច្ចដ៏រឹងមាំមួយនៅការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ជារួម ដោយផ្អែកតាមនិន្នាការ និងសភាពការណ៍ទេសចរណ៍នាពេលបច្ចុប្បន្ន ពិសេសភាពជាដៃគូរវាងភាគីរដ្ឋនិងភាគីឯកជន សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជានេះ នឹងជំរុញបាននូវការសម្របសម្រួល និងតម្រែតម្រង់ទិសលើការផ្សព្វផ្សាយទាក់ទងនឹងវិស័យទេសចរណ៍ យុទ្ធសាស្ត្រផ្សព្វផ្សាយនិងទាក់ទាញទេសចរណ៍ និងការចូលរួមបើកស្ថានតំណាង ឬកិច្ចសហការជាមួយសមាគមឬស្ថាប័នឯកជននានាដែលមានទីតាំងនៅក្រៅប្រទេស ដើម្បីពង្រឹងការផ្សព្វផ្សាយទេសចរណ៍ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់ព័ត៌មានអំពីវិស័យទេសចរណ៍កម្ពុជាទៅកាន់ភ្ញៀវទេសចរអន្តរជាតិសំដៅធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍មួយដ៏ទាក់ទាញនិងផ្តល់ភាពកក់ក្តៅ ពោលគឺសម្រេចបានការទាក់ទាញភ្ញៀវទេសចរឲ្យមានទស្សនាកម្ពុជាកាន់តែច្រើនថែមទៀតស្របតាមផែនការយុទ្ធសាស្ត្រ និងការដឹកនាំដ៏ត្រឹមត្រូវនិងឈ្លាសវៃរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន សម្តេចអគ្គសេនាបតីតេជោ ជាប្រមុខ[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ៕

[១] អត្ថបទនេះដកស្រង់ពីសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា។

# កិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ជាមួយក្រុមការងារ RIA នៃក្រសួងយុត្តិធម៌



កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំកិច្ចប្រជុំក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ជាមួយក្រុមការងារRIA របស់ក្រសួងយុត្តិធម៌ ដែលដឹកនាំដោយ ឯកឧត្តម **ជិន ម៉ាលីន** អនុរដ្ឋលេខាធិការ និងជាប្រធានក្រុមការងារ ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍វាយតម្លៃលើផលប៉ះពាល់ នៃសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌។

កិច្ចប្រជុំនេះក៏មានការចូលរួម ពីសំណាក់ ឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរង និងជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ឯកឧត្តម **អេង វត្ថមុនី** អគ្គលេខាធិការរង និងជាប្រធានផ្នែកបណ្តុះបណ្តាលនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងសហការីមួយចំនួនទៀត រីឯខាងក្រុមការងារ



RIA របស់ក្រសួងយុត្តិធម៌ ក៏មានការចូលរួមពីសំណាក់ លោកជំទាវ **ម៉ែន សុមាធា** អគ្គនាយក លោក **សុខ មុរ៉ា** ប្រធាននាយកដ្ឋាន និងសហការីមួយចំនួនទៀត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **យឹម ណុលសន** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារ RIA របស់ក្រសួងយុត្តធម៌ ដែលបានចូលរួមយ៉ាងសកម្មក្នុងការងារ RIA និងបានសហការយ៉ាងល្អជាមួយក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ ECOSOCC និងជាពិសេសបានប្រឹងប្រែងរៀបចំរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌ ដោយបានប្រើប្រាស់វិធីសាស្ត្រRIA ទទួលបានលទ្ធផលល្អប្រសើរ។



ឯកឧត្តម **យឹម ណុលសន**

បញ្ហាចម្បងនៃការរៀបចំឲ្យមានប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌ គឺសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត មានចំនួនច្រើនពេក ដែលភាគច្រើនជាសំណុំតូចតាចដែលអាចសម្រុះសម្រួលនៅថ្នាក់មូលដ្ឋានបាន ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ជាពិសេសនៅតំបន់ដាច់



ស្រយាលមិនមានការយល់ដឹងពីផ្លូវច្បាប់ និងនីតិវិធីតុលាការក្នុងការដោះស្រាយវិវាទ មន្ត្រីបម្រើការងារសុទ្ធសឹងជាមន្ត្រីស្ម័គ្រចិត្តគ្មានក្របខណ្ឌ គ្មានប្រាក់បៀវត្ស មិនមានការិយាល័យធ្វើការច្បាស់លាស់ កិច្ចសហការជាមួយសាលាដំបូងរាជធានី ខេត្ត និងអាជ្ញាធរមូលដ្ឋានមិនមានភាពរលូន។



កិច្ចប្រជុំបានដំណើរការទៅដោយរលូន ដែលមានលោក **សុខ ម៉ូរ៉ា** ប្រធាននាយកដ្ឋាន បានធ្វើបទបង្ហាញអំពីខ្លឹមសារនៃរបាយការវាយតម្លៃលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌ ជូនអង្គប្រជុំយ៉ាងក្បោះក្បាយ។

អង្គប្រជុំបានពិនិត្យពិភាក្សាលើ សេចក្តីព្រាងរបាយការណ៍ យ៉ាងយកចិត្តទុកដាក់ និងបានផ្តល់មតិយោបល់ ដើម្បីកែលម្អលើចំណុចខ្វះខាតបន្តិចបន្តួច ក្នុងន័យធ្វើឲ្យរបាយការណ៍កាន់តែមានតម្លៃសម្រាប់ការគាំទ្រដល់សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌ ដែលនឹងដាក់ជូន ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងយុត្តធម៌ ពិនិត្យសម្រេច នៅពេលខាងមុខ៕

# III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០២/១៨<br>ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត និងប្រកាសសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ អគារសិក្សាថ្មី "អគារទេពកោសល្យវិស្វកម្ម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**" នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ២ | ០១/០២/១៨<br>ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។<br>៤-សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០២/០២/១៨<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ។<br>៣-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។<br>៤-សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ០៣/០២/១៨<br>ម៉ោង០៨:០០នាទី | ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលនៃមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស និងណែនាំអំពីផែនការអនុវត្តជាក់ស្តែងឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ នៅទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៥ | ០៤/០២/១៨ ម៉ោង០៨:៣០នាទី | ចូលរួមជាអធិបតី ក្នុងពិធីផ្សព្វផ្សាយស្តីពីច្បាប់ នីតិវិធីបោះឆ្នោត និងគោលនយោបាយរបស់បក្សជូនអង្គបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៦ | ០៦/០២/១៨ ម៉ោង០៩:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **យឹម ណុលសន** និងឯកឧត្តម **ឆយ អួន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៧/០២/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅតំបន់ទំនប់កប់ស្រូវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |
| ៨ | ០៨/០២/១៨ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១០/០២/១៨ ម៉ោង០៨:០០នាទី | ចូលរួមពិធីហែក្បួនព្យុហយាត្រា បើកយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ របស់មណ្ឌលបោះឆ្នោតភូមិភាគទី៥ ក្នុងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្ត តាកែវ។ |
| ១០ | ១២/០២/១៨ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១៣/០២/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត សាកលវិទ្យាល័យវេស្ទើន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌល សន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១២ | ១៤/០២/១៨ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីពិភាក្សាលើគម្រោងសាងសង់សម្រាប់ឆ្នាំ២០១៨ របស់ក្រុមហ៊ុន SCA និងកំណត់នូវគោលការណ៍ណែនាំដល់ក្រុមហ៊ុន SCA លើគម្រោងវិនិយោគសម្រាប់ឆ្នាំបន្តបន្ទាប់ រហូតដល់មានការដាក់ឲ្យដំណើរការអាកាសយានដ្ឋានអន្តរជាតិថ្មី ភ្នំពេញ និងសៀមរាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ១៣ | **១៥/០២/១៨ ម៉ោង១៤:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងាររបស់ខេត្តតាកែវ ឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅសាលមហោស្រពខេត្តតាកែវ។ |
| ១៤ | **១៩/០២/១៨ ម៉ោង១១:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុខជ្វានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២១/០២/១៨ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅតំបន់វត្តទឹកថ្លា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ |
| ១៦ | **២២/០២/១៨ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំ ខែមករា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៧/០២/១៨ ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបការងារទេសចរណ៍ឆ្នាំ២០១៧ និងទិសដៅអនុវត្តន៍បន្តឆ្នាំ២០១៨ និងកម្មវិធីទិវាជាតិទីក្រុងស្អាតលើកទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។ |
| ១៨ | **២៨/០២/១៨ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិរំដួង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ |
| ១៩ | **២៨/០២/១៨ ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារទេសចរណ៍ឆ្នាំ២០១៧ និងទិសដៅអនុវត្តន៍បន្តឆ្នាំ២០១៨ និងកម្មវិធីទិវាជាតិទីក្រុងស្អាតលើកទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។ |

# ព្រឹត្តិបត្រព័ត៌មាន




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in